ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ៖ ១០៩ ·ក១·ក្រ.១១

ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៥០៧៨

ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ៖ ៣៨៨៤

ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ៖ ៦១៩៧

ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០២ និង ៣០ នាទីរសៀល នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ជាចៅក្រមប្រឹក្សា

លោកស្រី ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៥០៧៨ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] **សែណារ៉ាល់** ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សាសនាឥស្លាម មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិ [redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៧៤ ផ្លូវលំ ភូមិព្រែកតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] រ៉ែសេត(ស្លាប់) ម្តាយឈ្មោះ [redacted] រ៉ែស៉់ម៉ាស់(រស់) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន៖ គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖៨៤៩៩ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ នៅមណ្ឌលអប់រំកែប្រែទី១(ម១)។

ជាប់ចោទពីបទ: **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ(ប្រើដៃទាញចំរឹងបន្ទួច)និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខផ្ទះទុកចោលលេខ១សជ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា២៧ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោកមេធាវី [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកនៃក្រុមមេធាវី អ៊ុល អេ វ៉ាយ និងសហការីដែលមានអាសយដ្ឋាននៅផ្ទះលេខ១២ ផ្លូវ៣៨៤ ភូមិ៥ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សែណារ៉ាល់** ។

### អង្គហេតុនៃរឿងមានដូចតទៅ:

-កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៩ និង០០នាទី ជនរងគ្រោះឈ្មោះ [redacted] សារ៉ុ ភេទប្រុស បានមក



Scanned with CamScanner

មើលផ្ទះដែលទុកចោលរយៈពេល២ឆ្នាំ នៅចំណុចផ្ទះលេខ១សជ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏ឃើញជនជាប់ចោទឈ្មោះ [redacted] សែណាល់ ភេទប្រុស អាយុ២៤ឆ្នាំ បានផ្តោះរបងចូលផ្ទះជនរងគ្រោះបានយកដែទាញចំរឹងបង្អួចរកលួចទ្រព្យសម្បត្តិ ពេលនោះជនរងគ្រោះក៏រាយការណ៍ប្រាប់សមត្ថកិច្ចឱ្យឃាត់ខ្លួនជនសង្ស័យ។ បន្ទាប់មកសមត្ថកិច្ចបានយកទឹកនោមរបស់ជនជាប់ចោទទៅធ្វើតេស្តជាលទ្ធផលគឺវិជ្ជមាន(មានសារធាតុញៀន)។

-បានឃើញ របាយការណ៍សំយោគលេខ ០៧១/២០ រ.ប.ក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៣៦៤៣ អ.យ.ឈ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៥៦៣៣ អ.យ.ឈ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាដំណោះស្រាយលេខ: ៧៣២៥ "ទ" ជ.ជ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **ទំសេណាល់** បានឆ្លើយនាពេលសវនាការថា៖ ខ្លួនសូមបដិសេធចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ចោលទាំងស្រុង។ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៩ ព្រឹក មីងម្នាក់នៅក្បែរផ្ទះខ្លួនប្តីគាត់ឈឺ បានពឹងខ្លួនទៅបេះថ្នាំប្រក់ផ្លែនៅផ្ទះគេទុកចោល នៅពេលនោះខ្លួនបានទៅម្នាក់ឯង ដោយផ្ទះនោះគេទុកចោលមានរបងថ្មព័ទ្ធជុំវិញ ហើយខ្លួនបានផ្តោះរបងចូលទៅ បេះដើមថ្នាំប្រក់ផ្លែបានប្រហែល ០៤ដើម ហើយខ្លួនមិនបានទៅប៉ះពាល់របស់របរគេនៅខាងក្នុងផ្ទះគេទេ ស្រាប់តែពេលនោះឃើញសមត្ថកិច្ចជិះម៉ូតូល្បាតមកដល់ហៅខ្លួនឱ្យចេញមកក្រៅនិងបានឃាត់ខ្លួន ដោយចោទថាខ្លួនបានលួចរបស់គេ សមត្ថកិច្ចបានយកទឹកនោមទៅធ្វើតេស្តឃើញមានសារធាតុញៀន ខ្លួនចេះប្រើប្រាស់គ្រឿងញៀនជិត០១ឆ្នាំមកហើយ មិនធ្លាប់លក់ដូរគ្រឿងញៀនទេ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារុំ** បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ៖ មុនដំបូងរូបខ្លួន និងក្រុមគ្រួសារបានចាក់សោរទ្វារផ្ទះលេខ១សជ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ទុកចោលរយៈពេល០២ឆ្នាំមកហើយ រួចទៅរស់នៅនៅផ្ទះផ្សេងទៀតនៅខណ្ឌពោធិ៍សែនជ័យ។ លុះដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៩ និង០០ នាទី រូបខ្លួនបានមកមើលផ្ទះខាងលើក៏ឃើញមនុស្សប្រុសម្នាក់បានផ្តោះរបងចូលផ្ទះរបស់ខ្លួនយកដែទាញចំរឹងបង្អួចរកលួចទ្រព្យសម្បត្តិ ពេលនោះខ្លួនបានរាយការណ៍ប្រាប់សមត្ថកិច្ចចុះមកឃាត់ខ្លួនជនជាប់ចោទ និងបញ្ជូនជនជាប់ចោទមកអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅតែម្តង។ កន្លងមករូបខ្លួនបានធ្លាប់បាត់ទ្រព្យសម្បត្តិនៅផ្ទះខាងលើរួមមាន៖ទ្វារឈើ១,ទ្វារដែក១,បន្ទះស្ទូឡា០១,ទុយោទឹក១០ដើម, ទូរទស្សន៍០១គ្រឿង,កម្រាលព្រំ០១គូរ,ធុងហ្គាស០១,លួសបន្លាប្រវែង៥០ម៉ែត្រ,បង្អួចកញ្ចក់០៣ផ្ទាំង,តុឈើ០៣ ចានមួយចំនួន និងសម្ភារៈមួយចំនួនទៀត។

-សាក្សីឈ្មោះ [redacted] **មេសំ** បានឆ្លើយនាពេលសវនាការថា៖ខ្លួនបានស្បថរួចហើយ ហើយខ្លួនបានបញ្ជាក់ទៀតថាខ្លួនគឺជាអ្នកជិតខាងរបស់ជនជាប់ចោទ។ ជនជាប់ចោទមិនបានលួចដូចការប្រកាន់នោះទេ គឺជនជាប់ចោទបានចូលទៅបេះថ្នាំឱ្យប្អូនប្រុសរបស់ខ្លួន។ នៅថ្ងៃកើតហេតុនោះខ្ញុំទៅលក់ មិនបាននៅក្នុងហេតុការនោះទេ ពេលមកដល់វិញទើបលឺគេនិយាយ។ ខ្លួនបានបញ្ជាក់ទៀតថាជនជាប់ចោទមិនដែលបានលួចរបស់គេនោះទេ។មូលហេតុដែលខ្លួនដឹងគឺអ្នកប្រើជនជាប់ចោទឱ្យទៅ



Scanned with CamScanner

បេះថ្នាំគឺជាប្រពន្ធរបស់ប្អូនប្រុសខ្លួន។ខ្លួនដឹងថាជនជាប់ចោទប្រើប្រាស់ថ្នាំញៀន ប៉ុន្តែមិនដែលលួចរបស់គេទេ គឺអ្នកដទៃជាអ្នកលួច មិនមែនជនជាប់ចោទលួចដូចការចោទប្រកាន់នោះទេ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទរួចមក ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ តាមអង្គហេតុវត្ថុដែលចាប់យកជាក់ស្តែង មានភាពស៊ីសង្វាក់បញ្ជាក់ថាជនជាប់ចោទពិតជាបាន **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ(ប្រើដៃទាញចំរឹងបន្លួច)និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខផ្ទះចុកចោលលេខ១សជ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ពិតមែន ហេតុដូចនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់លើជនជាប់ចោទដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ: ៥៦៣៣ អ.យ.ឈ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ដដែល និងស្នើសុំទៅក្រុមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសន្និដ្ឋាននាពេលសវនាការថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តិដូចការចោទប្រកាន់នោះទេ ហើយកូនក្តីរបស់ខ្លួនរបស់ខ្លួនបានបដិសេធចម្លើយតាំងពីដំណាក់កាលអយ្យការរហូតមក ដូចនេះស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សៃណារ៉ាល់** ភេទប្រុស អាយុ២៤ឆ្នាំ ស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោស និងជួយរកយុត្តិធម៌ឱ្យខ្លួនផង។

## តុលាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.តាមអង្គហេតុ និងលទ្ធផលសួរដេញដោលដែលស៊ីសង្វាក់ទៅនឹងលទ្ធផលស៊ើបសួរ បង្ហាញអោយឃើញថា កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ នៅចំណុចចុកចោលលេខ១សជ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ពិតជាមានអង្គហេតុ **ប៉ុនប៉ងលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **សៃណារ៉ាល់** ពិតប្រាកដមែន។

២.ជនជាប់ចោទឈ្មោះ [redacted] **សៃណារ៉ាល់** ត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់បញ្ជូនមកតុលាការជំនុំជំរះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៦៤៣ អ.យ.ឈ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០



Scanned with CamScanner

ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ(ប្រើដៃទាញចំរឹងបង្អួច)និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**បទល្មើសដែលមានបញ្ញត្តិចែងឱ្យផ្តន្ទាទោសតាមមាត្រា២៧ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញាត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ជនជាប់ចោទឈ្មោះ [redacted] **សែណាល់** បានឆ្លើយថា៖ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៩ព្រឹក មីងម្នាក់នៅក្បែរផ្ទះខ្លួនប្តីគាត់ឈឺ បានពឹងខ្លួនទៅបេះផ្លែប្រក់១ផ្លែនៅផ្ទះគេទុកចោល នៅពេលនោះខ្លួនបានទៅម្នាក់ឯង ដោយផ្ទះនោះគេទុកចោលមានរបងថ្មព័ទ្ធជុំវិញ ហើយខ្លួនបានផ្លោះរបងចូលទៅ បេះដើមថ្នាំប្រក់ផ្លែបានប្រហែល០៤ដើម ហើយខ្លួនមិនបានទៅប៉ះពាល់របស់របរគេនៅខាងក្នុងផ្ទះគេទេ ស្រាប់តែពេលនោះឃើញសមត្ថកិច្ចជិះម៉ូតូល្បាតមកដល់ហៅខ្លួនឱ្យចេញមកក្រៅនិងបានឃាត់ខ្លួន ដោយចោទថាខ្លួនបានលួចរបស់គេ សមត្ថកិច្ចបានយកទឹកនោមទៅធ្វើតេស្តឃើញមានសារធាតុញៀន ខ្លួនចេះប្រើប្រាស់គ្រឿងញៀនជិត០១ឆ្នាំមកហើយ មិនធ្លាប់លក់ដូរគ្រឿងញៀនទេ។

តាមចម្លើយសារភាពរបស់ជនជាប់ចោទថាមិនបានប៉ុនប៉ងលួចនោះ មិនអាចឱ្យតុលាការជឿបានទេ ដោយហេតុថាជនជាប់ចោទបានឆ្លើយនៅក្នុងកំណត់សួរចម្លើយរបស់នគរបាលយុត្តិធម៌ ខ្លួនបានដើរចេញពីផ្ទះ ដើម្បីរកលួចទ្រព្យសម្បត្តិគេ ក៏ឃើញផ្ទះគេទុកចោលគ្មានមនុស្សនៅ ខ្លួនបានផ្លោះរបងចូល យកដៃទៅទាញចម្រឹងបង្អួចគេរកលួចទ្រព្យសម្បត្តិ ក៏ត្រូវបានសមត្ថកិច្ចមកទាន់ឃាត់ខ្លួន។ចម្លើយសារភាពរបស់ជនជាប់ចោទនៅតំណាក់កាលនគរបាលយុត្តិធម៌អាចឱ្យតុលាការជឿបានដោយគ្មានភស្តុតាងផ្ទុយនោះទេ។ផ្អែកតាមមាត្រា១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់ “ឯកសារដើម” មានន័យថា ត្រូវទុកជាឯកសាររហូតដល់មានភស្តុតាងផ្ទុយ។ ចម្លើយបដិសេធរបស់ជនជាប់ចោទមិនមែនជាភស្តុតាងផ្ទុយនោះឡើយ។

៤. តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារុំ** បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ៖មុនដំបូងរូបខ្លួន និងក្រុមគ្រួសារបានចាក់សោរទ្វារផ្ទះលេខ១សជ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រាខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ទុកចោលរយៈពេល០២ឆ្នាំមកហើយ រួចទៅរស់នៅនៅផ្ទះផ្សេងទៀតនៅខណ្ឌពោធិ៍សែនជ័យ។ លុះដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៩ និង០០ នាទី រូបខ្លួនបានមកមើលផ្ទះខាងលើក៏ឃើញមនុស្សប្រុសម្នាក់បានផ្លោះរបងចូលផ្ទះរបស់ខ្លួនយកដៃទាញចំរឹងបង្អួចរកលួចទ្រព្យសម្បត្តិ ពេលនោះខ្លួនបានរាយការណ៍ប្រាប់សមត្ថកិច្ចចុះមកឃាត់ខ្លួនជនជាប់ចោទ និងបញ្ជូនជនជាប់ចោទមកអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅតែម្តង។កន្លងមករូបខ្លួនបានធ្លាប់បាត់ទ្រព្យសម្បត្តិនៅផ្ទះខាងលើរួមមាន៖ទ្វារឈើ១,ទ្វារដែក១,បន្ទះសូឡា០១,ទុយោទឹក១០ដើម,ទូរទស្សន៍០គ្រឿង, កម្រាលព្រំ០១គូរ,ធុងហ្គាស០១,លួសបន្លាប្រវែង៥០ម៉ែត្រ,បង្អួចកញ្ចក់០៣ផ្ទាំង,តុឈើ០៣ ចានមួយចំនួន និងសម្ភារៈមួយចំនួនទៀត។

ចម្លើយរបស់ជនរងគ្រោះ អាចឱ្យតុលាការជឿបានថា ជនជាប់ចោទ ពិតជាបានប៉ុនប៉ង ចូលលួចយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះពិតប្រាកដមែន។

៥.ជនជាប់ចោទឈ្មោះ [redacted] **សែណាល់** ពិតជាមានចេតនាទុច្ចរិតក្នុងការដកហូតនូវទ្រព្យសម្បត្តិអ្នកដទៃ តែត្រូវបានអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។

៦.អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅលើមាត្រា២៧ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧.ជនជាប់ចោទឈ្មោះ [redacted] **សែណាល់** ជានីតិជន ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវ

ព្រហ្មទណ្ឌ។ ជនជាប់ចោទអាចយល់ដឹងបានអំពើផលវិបាកដែលខ្លួនបានប្រព្រឹត្ត តែជនជាប់ចោទនៅតែប្រព្រឹត្តដោយចេតនា។

៨.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **មេសំ** បានឆ្លើយនាពេលសវនាការថា៖ខ្លួនបានស្បថរួចហើយ ហើយខ្លួនបានបញ្ជាក់ទៀតថាខ្លួនគឺជាអ្នកជិតខាងរបស់ជនជាប់ចោទ។ ជនជាប់ចោទមិនបានលួចដូចការប្រកាន់នោះទេ គឺជនជាប់ចោទបានចូលទៅបេះថ្នាំឱ្យប្អូនប្រុសរបស់ខ្លួន។ នៅថ្ងៃកើតហេតុនោះខ្លួនទៅលក់ មិនបាននៅក្នុងហេតុការនោះទេ ពេលមកដល់វិញទើបលឺគេនិយាយ។ខ្លួនបានបញ្ជាក់ទៀតថាជនជាប់ចោទមិនដែលបានលួចរបស់គេនោះទេ។មូលហេតុដែលខ្លួនដឹងគឺអ្នកប្រើជនជាប់ចោទឱ្យទៅបេះថ្នាំគឺជាប្រពន្ធរបស់ប្អូនប្រុសខ្លួនតែគាត់បានស្បថរួចហើយ។ខ្លួនដឹងថាជនជាប់ចោទប្រើប្រាស់ថ្នាំញៀន ប៉ុន្តែមិនដែលលួចរបស់គេទេ គឺអ្នកដទៃជាអ្នកលួច មិនមែនជនជាប់ចោទលួចដូចការចោទប្រកាន់នោះទេ។

ចម្លើយសាក្សីនេះមិនអាចឱ្យតុលាការយកមកពិចារណាបានោះទេ ដោយហេតុថាសាក្សីគ្រាន់តែបញ្ជាក់ពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទថា មិនដែលលួចគេនោះ មិនអាចជាភស្តុតាងដោះបន្ទុកឱ្យជនជាប់ចោទនោះទេ។

៩.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ វត្ថុដែលចាប់យកជាក់ស្តែង និងមានភាពស៊ីសង្វាក់បញ្ជាក់ថាជនជាប់ចោទពិតបានប្រព្រឹត្តអំពោះ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ(ប្រើដៃទាញចំរឹងបន្ទួច)និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ពិតមែន ហេតុដូចនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់លើជន ជាប់ចោទដូចក្នុង តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៦៤៣ អ.យ.ឈ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ដដែល មានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណា។

១០.សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តិអំពើលួចដូចការចោទប្រកាន់នោះ តុលាការមិនអាចទទួលយកមកពិចារណាទេ ពីព្រោះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សន្និដ្ឋានផ្អែកទៅតាមចម្លើយរបស់ជនជាប់ចោទប៉ុណ្ណោះ ដោយគ្មានភស្តុតាងដោះបន្ទុកនោះទេ។

១១.អំពើរបស់ជនជាប់ចោទដែលបានផ្លោះរបងចូលទៅក្នុងបរិវេណផ្ទះជនរងគ្រោះ គោលបំណងគឺរកលួចយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះគឺមានភស្តុតាងច្បាស់លាស់ និងត្រូវបានមន្ត្រីនគរបាលចាប់ឃាត់ខ្លួនជាជាក់ស្តែងទៀតផង តែមិនមានធាតុផ្សំជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារអំពើគាស់ទំលុះទម្លាយនោះទេ ពីព្រោះគ្មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទបានគាស់ទំលុះទម្លាយទ្វាររបងឬទ្វារផ្ទះរបស់ជនរងគ្រោះនោះឡើយ គប្បីតុលាការកែប្រែបទចោទឱ្យបានត្រឹមត្រូវតាមអំពើនៃអង្គហេតុពីមាត្រា៣៥៧ មកមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១២.សកម្មភាពរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ និងខូចខាតដល់ទ្រព្យសម្បត្តិអ្នកដទៃ ព្រមទាំងបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ដែលអំពើនេះត្រូវបានកំណត់ថាជាបទល្មើស**ប៉ុនប៉ងលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា២៧ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៃព្រះរាជាណាចក្រកម្ពុជា គប្បីតុលាការសំរេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

១៣.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សៃណាល់** ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ពីបទ ៖ **ប៉ុនប៉ងលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខផ្ទះទុកចោលលេខ១សជ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែ

កក្កដា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា២៧ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញាត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៤.សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សៃណណាល់ សុំតុលាការមេត្តាជួយបន្ធូរបន្ថយទោស និងជួយរកយុត្តិធម៌ឱ្យខ្លួនផង។

## ហេតុដូច្នេះសម្រេច

១.កែប្រែបទចោទលើឈ្មោះ [redacted] **សៃណណាល់** ពីបទ:**ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោស** តាមមាត្រា៣៥៧ មកជាបទ:**ប៉ុនប៉ងលួច** តាមមាត្រា២៧ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សៃណណាល់**(អត្តសញ្ញាណដូចខាងលើ)ដាក់ពន្ធនាគារ០១(មួយ)ឆ្នាំ។

ពីបទ:**ប៉ុនប៉ងលួច និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅផ្ទះចុកចោលលេខ១សផ ផ្លូវបេតុង ភូមិព្រៃតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា២៧ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញាត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សៃណណាល់** ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ | ហត្ថលេខា និង ត្រា ៖ |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ០៥រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]